ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ELECTRICITE DU CAMBODGE

អគ្គិសនីកម្ពុជា

លេខ : ០២៥០ សជណ.អកក.១៩

# សេចក្តីជូនដំណឹង

## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើស**បុគ្គលិក ចំនួន ១៧ រូប** ដើម្បីចូលបម្រើការងារនៅ អគ្គិសនីត្បូងឃ្មុំ នៃអគ្គិសនីកម្ពុជា ដូចខាងក្រោម :

*-**លក្ខណៈសម្បត្តិបេក្ខជន** :

**១. ភ្នាក់ងារស្រង់ថាមពល, ភ្នាក់ងារដំឡើង ថែទាំ និងជួសជុលបណ្តាញ LV, ភ្នាក់ងារដំឡើង ថែទាំ និងជួសជុលបណ្តាញ MV, បុគ្គលិកបច្ចេកទេស GIS** សរុបចំនួន ០៤ រូប :

- បេក្ខជនភេទប្រុស, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា សញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនី ឡើងទៅ

**២. បុគ្គលិករដ្ឋបាល, បុគ្គលិកទទួលអតិថិជនតាមទូរស័ព្ទ (Hot line), បុគ្គលិកគ្រប់គ្រងគណនី, បុគ្គលិកគ្រប់គ្រងបំណុល, បុគ្គលិកឃ្លាំងសម្ភារ និងប្រេងឥន្ធនៈ** សរុបចំនួន ០៨ រូប:

- បេក្ខជនទាំងពីរភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ឡើងទៅ

**៣. បុគ្គលិកគណនេយ្យ** ចំនួន ០១ រូប :

- បេក្ខជនទាំងពីរភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា បរិញ្ញាបត្រគណនេយ្យ ឡើងទៅ

**៤. បុគ្គលិកបេឡា សាខាពញាក្រែក** ចំនួន ០១ រូប :

- បេក្ខជនភេទស្រី, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ឡើងទៅ

**៥. ភ្នាក់ងារត្រួតពិនិត្យ** ចំនួន ០២ រូប :

- បេក្ខជនទាំងពីរភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.I.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា វិស្វករអគ្គិសនី ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Program AutoCAD

**៦. អ្នកបើកបររថយន្តស្ទូច** ចំនួន ០១ រូប :

- បេក្ខជនភេទប្រុស, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ឡើងទៅនិងមាន ប័ណ្ណបើកបររថយន្តប្រភេទ "ឯ_ក" ឬ "ឯ_ឃ" និងចេះបើកបររថយន្តស្ទូច

*- **បញ្ជាក់** : ប្រសិនបើលទ្ធផលពិន្ទុប្រហាក់ប្រហែលគ្នា គឺផ្តល់អទិភាពជូន

- ជនពិការ
- បេក្ខនារីគ្រប់ខេត្ត-ក្រុង និងបេក្ខជន មានអាសយដ្ឋានស្ថិតនៅខេត្តសាមី ។

*- ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជាបេក្ខជនត្រូវទាញយក(**Download**) ដោយផ្ទាល់ពីក្នុងគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : **www.EDC.com.kh** ត្រង់ចំណុចព័ត៌មានវិជ្ជាជីវៈ ដោយចុចលើពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅ អគ្គិសនីកម្ពុជា ។

*- បេក្ខជនត្រូវបំពេញពាក្យសុំចូលបម្រើការងារ និងត្រូវអញ្ជើញមកដាក់ពាក្យប្រឡងដោយផ្ទាល់ខ្លួន និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ច្បាប់ដើមមកជាមួយ ។ ករណី បេក្ខជនមិនបានអញ្ជើញមកដាក់ពាក្យដោយផ្ទាល់ទេ អគ្គិសនីកម្ពុជា មិនទទួលពាក្យជូនឡើយ ។

*- **<u>បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ</u>** :

| | |
|---|---|
| - ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារ នៅអគ្គិសនីកម្ពុជា | ចំនួន ០១ ច្បាប់ |
| - ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ | ចំនួន ០១ ច្បាប់ |
| - កិច្ចសន្យា សម្រាប់បំពេញពាក្យសុំចូលបម្រើការងារ និងកិច្ចសន្យាការងារ | ចំនួន ០១ ច្បាប់ |
| - សលាកប័ត្របេក្ខជន | ចំនួន ០១ ច្បាប់ |
| - ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ | ចំនួន ០១ ច្បាប់ |
| - តារាងពិន្ទុ (TRANSCRIPT) | ចំនួន ០១ ច្បាប់ |
| - ច្បាប់ដើម និងច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន | ចំនួន ០១ ច្បាប់ |
| - ច្បាប់ចម្លងប័ណ្ណបើកបររថយន្ត កម្រិត "ឯ$_{ក}$" ឬ"ឯ$_{ឃ}$" (សម្រាប់បុគ្គលិកបើកបររថយន្តស្ទូច) | ចំនួន ០១ ច្បាប់ |

*- **ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធI នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រឡងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម ។**

*- **ទីកន្លែងទទួលពាក្យ : នៅអគារ B ជាន់ទី១ ការិយាល័យបុគ្គលិក នៃអគ្គិសនីកម្ពុជា**
ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០ ។

*- **<u>ព័ត៌មានផ្សេងៗ</u>** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

ថ្ងៃ អង្គារ ១០កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៩

**ជ. រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកអគ្គិសនីកម្ពុជា**
**អគ្គនាយករង**

ELECTRICITE DU CAMBODGE

**កេង_គន្ធា**

**<u>បញ្ជាក់</u>**

- សេចក្តីជូនដំណឹងនេះ ធ្វើកាផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់ អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុច " ព័ត៌មានវិជ្ជាជីវៈ " ។